# Electroconvulsive therapy

About your rights

# ការព្យាបាលដោយវិធីឆក់ខ្សែភ្លើង

អំពីសិទ្ធិរបស់លោកអ្នក

Cambodian

## សេចក្តីសង្ខេប

បើគ្រូពេទ្យសរសៃប្រសាទលោកអ្នកសំរេចស្នើសុំឲ្យលោកអ្នកទទួលការព្យាបាលដោយវិធីឆក់ខ្សែភ្លើង (ECT) លោកអ្នក៖

- នឹងទទួលព័ត៌មានអំពី ECT ហើយអាចសួរសំណួរអំពីការព្យាបាលនេះ
- មានសិទ្ធិបដិសេធមិនទទួល ECT បើលោកអ្នកមានសមត្ថភាពផ្តល់ការអនុញ្ញាតដែលជ្រាបដឹងព័ត៌មានចំពោះការព្យាបាលនោះ
- មានសិទ្ធិទទួលឱវាទផ្នែកពេទ្យនិងផ្លូវច្បាប់
- មានសិទ្ធិទទួលយោបល់ទីពីរពីគ្រូពេទ្យសរសៃប្រសាទ អំពី ECT
- មានសិទ្ធិក្នុងការសុំឲ្យមិត្តភក្តិ សមាជិកគ្រួសារ ឬមេធាវី តំណាងឲ្យលោកអ្នក
- អាចធ្វើបណ្តឹងអំពីការព្យាបាលរបស់លោកអ្នក
- មានសិទ្ធិនៅក្រោម*លក្ខន្តិកៈនៃសិទ្ធិមនុស្សនិងការទទួលខុសត្រូវ*។

លោកអ្នកអាចសុំឲ្យសមាជិកណាមួយនៃក្រុមព្យាបាល មិត្តភក្តិ សមាជិកគ្រួសារ មេធាវី និងអ្នកគាំទ្រ ឬអ្នកសាកសួរសុខទុក្ខមកពីសហគមន៍ ជួយលោកអ្នកក្នុងការអនុវត្តកិច្ចការទាំងនេះ ឬទាក់ទងអង្គការមួយក្នុងចំណោមអង្គការទាំងឡាយដែលមានរាយឈ្មោះនៅខាងចុងបញ្ចប់នៃកូនសៀវភៅនេះ។

## ការព្យាបាលដោយវិធីឆក់ខ្សែភ្លើង

### អំពីសិទ្ធិរបស់លោកអ្នក

លោកអ្នកបានទទួលកូនសៀវភៅនេះដោយសារតែវេជ្ជបណ្ឌិតឬ គ្រូពេទ្យសរសៃប្រសាទលោកអ្នកបានសំរេចស្នើឡើងថា លោកអ្នកនឹងទទួលប្រយោជន៍ពី ECT ។ កូនសៀវភៅនេះផ្តល់ព័ត៌មានអំពីសិទ្ធិផ្លូវច្បាប់និងសិទ្ធិទទួលរបស់លោកអ្នកនៅក្រោម *ច្បាប់សុខភាពផ្លូវចិត្ត ឆ្នាំ 1986 (Mental Health Act 1986)* ។

គ្រូពេទ្យសរសៃប្រសាទលោកអ្នកឬសមាជិកនៃក្រុមព្យាបាលនឹងពិភាក្សាជាមួយលោកអ្នកអំពីព័ត៌មាននេះព្រមទាំងសិទ្ធិនិងសិទ្ធិទទួលរបស់លោកអ្នក ហើយឆ្លើយនឹងសំណួររបស់លោកអ្នក។

ព័ត៌មាននេះត្រូវតែពន្យល់ជាភាសាឬតាមលក្ខណៈមួយដែលលោកអ្នកអាចយល់បាន។ កូនសៀវភៅនេះត្រូវបានបកប្រែជាភាសាមួយចំនួនផងដែរ។ លោកអ្នកអាចសួរសមាជិកក្រុមព្យាបាលថាតើមានឯកសារនេះជាភាសាដែលលោកអ្នកចង់បានដែរឬទេ។

## មាតិកា


| | |
|---|---|
| ECT: សិទ្ធិនិងសិទ្ធិទទួលរបស់លោកអ្នក | 2 |
| ECT: ព័ត៌មានអំពីការព្យាបាល | 3 |
| បណ្តឹង | 5 |
| ការទាក់ទងសំខាន់ៗ | 6 |


### ទូរស័ព្ទផ្តល់ព័ត៌មាន

លោកអ្នកអាចស្តាប់ព័ត៌មានថតទុកអំពីការព្យាបាលដោយវិធីឆក់ខ្សែភ្លើងជាភាសាមួយចំនួន តាមរយៈការទូរស័ព្ទទៅកាន់ទូរស័ព្ទផ្តល់ព័ត៌មាន។

លេខទូរស័ព្ទទាំងឡាយមាននៅខាងខ្នងនៃកូនសៀវភៅនេះ។

ទូរស័ព្ទទាំងនេះដំណើរការ ២៤ ម៉ោងក្នុងមួយថ្ងៃ ប្រាំពីរថ្ងៃក្នុងមួយអាទិត្យ។


A Victorian Government initiative

State Government Victoria

សេវា(កិច្ចបំរើ)សុខភាពផ្លូវចិត្តមានឯកសារនៃច្បាប់សុខភាពផ្លូវចិត្ត។

បើលោកអ្នកមានសំណួរអំពីព័ត៌មាននេះឬសិទ្ធិរបស់លោកអ្នកនៅគ្រាណាមួយនោះ សូមសុំឲ្យអ្នកណាម្នាក់ពន្យល់លោកអ្នក។ លោកអ្នកអាចសួរសមាជិកនៃក្រុមព្យាបាល មិត្តភក្តិ សមាជិកគ្រួសារ មេធាវី អ្នកគាំទ្រ ឬអ្នកសាកសួរសុខទុក្ខមកពីសហគមន៍។

## លក្ខន្តិកៈនៃសិទ្ធិមនុស្សនិងការទទួលខុសត្រូវ

*ច្បាប់លក្ខន្តិកៈនៃសិទ្ធិមនុស្សនិងការទទួលខុសត្រូវរដ្ឋវិចតូរីយ៉ា ឆ្នាំ 2006* ស្វែងរកការលើកកំពស់និងកិច្ចការពារសិទ្ធិមនុស្សជាក់លាក់។ លក្ខន្តិកៈនេះចែងអំពីសិទ្ធិដែលត្រូវការពារ និងតម្រូវឲ្យសេវាសុខភាពផ្លូវចិត្តបំពេញការងារឲ្យសមស្របនឹងសិទ្ធិទាំងនេះ។

លក្ខន្តិកៈនេះក៏បញ្ជាក់ផងដែរនូវពេលនិងរបៀបដែលច្បាប់រឹតត្បិតសិទ្ធិទាំងឡាយ។ ឧទាហរណ៍៖ នៅក្រោមច្បាប់សុខភាពផ្លូវចិត្ត គេអាចឃាត់ខ្លួនលោកអ្នកឲ្យនៅក្នុងសេវាសុខភាពផ្លូវចិត្ត បើវាជាការចាំបាច់ដើម្បីការពារសុខភាពលោកអ្នកឬសុវត្ថិភាពរបស់អ្នកដទៃ។ ប៉ុន្តែការរឹតត្បិតណាមួយលើសេរីភាពលោកអ្នក និងការជ្រៀតជ្រែកណាមួយទៅនឹងសិទ្ធិ ភាពផ្ទាល់ខ្លួន កិត្តិយស និងការគោរពខ្លួនឯងរបស់លោកអ្នក ត្រូវបានធ្វើទៅតាមកំរិតទាបបំផុតដែលជាការចាំបាច់នៅក្នុងកាលៈទេសៈទាំងពួង។

បើលោកអ្នកមានសំណួរណាមួយអំពីលក្ខន្តិកៈនេះ ឬថាតើលក្ខន្តិកៈនេះប្រហែលជាមានផលប៉ះពាល់យ៉ាងណាលើការព្យាបាលលោកអ្នក សូមទាក់ទងអង្គការមួយក្នុងចំណោមអង្គការទាំងឡាយដែលមានរាយឈ្មោះនៅខាងចុងបញ្ចប់នៃកូនសៀវភៅនេះ។

# ECT: សិទ្ធិនិងសិទ្ធិទទួលរបស់លោកអ្នក

គ្រូពេទ្យសរសៃប្រសាទនឹងពិភាក្សាជាមួយលោកអ្នកអំពី ECT និងពន្យល់នូវរបៀបនៃការព្យាបាលនេះ ព្រមទាំងថាតើការព្យាបាលនេះ អាចជួយព្យាបាលជំងឺលោកអ្នកយ៉ាងណាដែរ។ គ្រូពេទ្យសរសៃប្រសាទនឹងពិភាក្សានូវលទ្ធភាពនៃផលវិបាកនិងការព្យាបាលជាជំរើសផ្សេងទាំងឡាយ សួរអំពីទស្សនៈរបស់លោកអ្នក ហើយឆ្លើយនឹងសំណួរណាមួយដែលលោកអ្នកអាចមាន។

នៅពេលដែលលោកអ្នកកំពុងពិភាក្សា ECT ជាមួយនឹងគ្រូពេទ្យសរសៃប្រសាទរបស់លោកអ្នក  លោកអ្នកអាចមានអ្នកណាមួយនៅជាមួយលោកអ្នកដើម្បីជាជំនួយ។ លោកអ្នកមានសិទ្ធិក្នុងការឲ្យមិត្តភក្តិ បងប្អូន មេធាវី ឬអ្នកគាំទ្រធ្វើជាតំណាងលោកអ្នក មុនពេលលោកអ្នកផ្តល់ការអនុញ្ញាតចំពោះ ECT ។

## ឱវាទនិងយោបល់ទីពីរ

លោកអ្នកមានសិទ្ធិក្នុងការទទួលឱវាទផ្លូវច្បាប់និងផ្លូវពេទ្យ។ លោកអ្នកក៏មានសិទ្ធិផងដែរក្នុងការទទួលយោបល់ទីពីរ អំពីថាតើលោកអ្នកត្រូវការ ECT ដែរឬទេ។ ប្រធានករណីឬគ្រូពេទ្យសរសៃប្រសាទលោកអ្នកអាចជួយលោកអ្នកក្នុងការរៀបចំឲ្យមានយោបល់ទីពីរ ក្នុងរង្វង់សេវាសុខភាពផ្លូវចិត្ត ឬមួយគេអាចជួយលោកអ្នកក្នុងការជ្រើសយកគ្រូពេទ្យសរសៃប្រសាទផ្ទាល់ខ្លួនលោកអ្នក។ លោកអ្នកប្រហែលជាត្រូវបង់ថ្លៃឈ្នួល បើលោកអ្នកជ្រើសយកគ្រូពេទ្យសរសៃប្រសាទឯកជន។

## ការផ្តល់ការអនុញ្ញាតចំពោះ ECT

បើលោកអ្នកអាចផ្តល់ការអនុញ្ញាតដែលមានការជ្រាបដឹងព័ត៌មាន លោកអ្នកអាចទទួល ECT តែនៅក្នុងករណីដែលលោកអ្នកយល់ព្រមប៉ុណ្ណោះ។ នេះមានន័យថា បើលោកអ្នកអាចផ្តល់ការអនុញ្ញាតដែលមានការជ្រាបដឹងព័ត៌មាន  លោកអ្នកមានសិទ្ធិបដិសេធមិនទទួល ECT ។

## ការអនុញ្ញាតដែលមានការជ្រាបដឹងព័ត៌មាន

ការអនុញ្ញាតដែលមានការជ្រាបដឹងព័ត៌មានគឺនៅពេលដែលលោកអ្នកយល់ព្រមទទួល ECT ក្រោយពីលោកអ្នកបានទទួលព័ត៌មានអំពី៖

- អ្វីៗដែលជាប់ពាក់ព័ន្ធនឹង ECT
- ប្រយោជន៍ ភាពមិនសុខស្រួល និងលទ្ធភាពគ្រោះថ្នាក់នៃ ECT
- ការព្យាបាលជាជំរើសណាមួយផ្សេងទៀតដែលមានប្រយោជន៍
- ចម្លើយទៅនឹងសំណួរទាំងអស់ដែលលោកអ្នកមានអំពី ECT ហើយលោកអ្នកបានយល់ចម្លើយទាំងនោះ
- ថាតើអ្នកដែលស្នើសុំឲ្យមាន ECT ឬវេជ្ជបណ្ឌិតដែលនឹងអនុវត្តការព្យាបាល មានទំនាក់ទំនងប្រាក់កាសជាមួយនឹងសេវា មន្ទីរពេទ្យ ឬគ្លីនិកដែលនឹងទទួល ECT
- សិទ្ធិផ្លូវច្បាប់ និងសិទ្ធិទទួលឯទៀតរបស់លោកអ្នក។

មុនពេលលោកអ្នកសំរេចថាតើលោកអ្នកចង់បាន ECT ឬទេនោះ ជាការសំខាន់ដែលលោកអ្នកជ្រាបដឹងព័ត៌មានឲ្យបានគ្រប់គ្រាន់។ បើលោកអ្នកមានសំណួរណាមួយ លោកអ្នកគួរសួរគ្រូពេទ្យសរសៃប្រសាទ ឬស្វែងរកឱវាទពីមិត្តភក្តិ សមាជិកគ្រួសារ មេធាវី ឬអ្នកគាំទ្រ ឬអង្គការមួយក្នុងចំណោមអង្គការទាំងឡាយដែលរាយឈ្មោះនៅខាងចុងបញ្ចប់នៃកូនសៀវភៅនេះ។

បើលោកអ្នកយល់ព្រមទទួល ECT គេនឹងសុំឲ្យលោកអ្នកចុះហត្ថលេខាលើក្រដាសបំពេញមួយដើម្បីបញ្ជាក់ថា លោកអ្នកបានផ្តល់ការអនុញ្ញាតដែលមានការជ្រាបដឹងព័ត៌មាន។

គ្រូពេទ្យសរសៃប្រសាទរបស់លោកអ្នកនឹងពិភាក្សាជាមួយលោកអ្នកអំពីចំនួននៃការព្យាបាលដែលស្នើសុំឲ្យធ្វើ។ លោកអ្នកអាចផ្តល់ការអនុញ្ញាតឲ្យមានការព្យាបាលដល់ទៅប្រាំមួយលើក។ បើវេជ្ជបណ្ឌិតលោកអ្នកជឿថា លោកអ្នកត្រូវការការព្យាបាលដើមដំបូងច្រើនជាងប្រាំមួយលើក នោះគេនឹងសុំឲ្យលោកអ្នកផ្តល់ការអនុញ្ញាតចំពោះវគ្គព្យាបាលនីមួយៗបន្ថែមទៀត ដែលមានការព្យាបាលចំនួនដល់ទៅប្រាំមួយលើក។

## ការដកការអនុញ្ញាត ECT ចេញ

បើលោកអ្នកយល់ព្រមឲ្យមាន ECT ប៉ុន្តែបន្ទាប់មកបានផ្លាស់ប្តូរចិត្ត លោកអ្នកមានសិទ្ធិដកការអនុញ្ញាតរបស់លោកអ្នកចេញនៅគ្រប់ពេលទាំងអស់ ហើយការព្យាបាលនេះនឹងមិនប្រព្រឹត្តទៅ

ឡើយ។ បើលោកអ្នកចង់ដកការអនុញ្ញាតរបស់លោកអ្នកចេញ លោកអ្នកគួរពិភាក្សាជាមួយនឹងគ្រូពេទ្យសរសៃប្រសាទរបស់លោកអ្នក។ សូមចងចាំថា លោកអ្នកអាចមានមិត្តភក្តិ សមាជិកគ្រួសារ មេធាវី ឬអ្នកគាំទ្រម្នាក់នៅជាមួយលោកអ្នក ដើម្បីផ្តល់ជំនួយឬតំណាងឲ្យលោកអ្នក។

## ECT បើលោកអ្នកមិនអាចផ្តល់ការអនុញ្ញាតដែលមានការជ្រាបដឹងព័ត៌មានទេនោះ

បើលោកអ្នកមិនអាចផ្តល់ការអនុញ្ញាតដែលមានការជ្រាបដឹងព័ត៌មានចំពោះ ECT ទេនោះ គ្រូពេទ្យសរសៃប្រសាទរបស់លោកអ្នកអាចផ្តល់ការអនុញ្ញាតជួសលោកអ្នក បើគ្រូពេទ្យនេះយល់ថា៖

- ECT គឺជាការចាំបាច់; ហើយ
- ស្ថានភាពរាងកាយឬផ្លូវចិត្តរបស់លោកអ្នក ទំនងជាដុនដាបទៅលុះត្រាតែលោកអ្នកមាន ECT; ហើយ
- មានការពិចារណាអំពីប្រយោជន៍និងលទ្ធភាពគ្រោះថ្នាក់នៃ ECT ព្រមទាំងការព្យាបាលមានប្រយោជន៍ឯទៀត។

គ្រូពេទ្យសរសៃប្រសាទរបស់លោកអ្នកនឹងពិភាក្សាជាមួយលោកអ្នកអំពី ECT មុនពេលលោកអ្នកទទួលការព្យាបាល។ កិច្ចខិតខំសមហេតុផលនឹងត្រូវបានធ្វើឡើងដើម្បីជំរាបអ្នកថែទាំចំបងរបស់លោកអ្នក (សមាជិកគ្រួសារឬមិត្តភក្តិដែលទទួលខុសត្រូវចំបងចំពោះការផ្តល់ជំនួយឬការថែទាំជូនលោកអ្នក) ឬអាណាព្យាបាលលោកអ្នក(បើលោកអ្នកមាន) អំពីសំណើនៃ ECT នេះ។

## ECT ជាបន្ទាន់

បើលោកអ្នកត្រូវការ ECT ជាបន្ទាន់ ដោយសារតែលក្ខណៈនៃជំងឺផ្លូវចិត្តរបស់លោកអ្នក ការព្យាបាលនេះអាចផ្តល់ជូនលោកអ្នកដោយគ្មានការអនុញ្ញាតរបស់លោកអ្នកឡើយ។ បើហេតុការណ៍នេះកើតមានឡើង គ្រូពេទ្យសរសៃប្រសាទរបស់លោកអ្នកនឹងពន្យល់លោកអ្នកនូវមូលហេតុដែលការព្យាបាលនេះត្រូវធ្វើជាបន្ទាន់។

# ECT: ព័ត៌មានអំពីការព្យាបាល

ផ្នែកនៃកូនសៀវភៅនេះ មានព័ត៌មានអំពី ECT ។

ECT ត្រូវបានប្រើអស់ពេលច្រើនឆ្នាំមកហើយសំរាប់ការព្យាបាលមានប្រសិទ្ធភាពចំពោះជំងឺផ្លូវចិត្តធ្ងន់ធ្ងរខ្លះ។ ការស្រាវជ្រាវបានបង្ហាញនូវប្រសិទភាពនៃ ECT ។ វិធីនេះបានកែលំអនៅពេលប៉ុន្មានឆ្នាំថ្មីៗនេះដើម្បីឲ្យទទួលលទ្ធផលប្រសើរឡើង ដោយមានផលវិបាកកាន់តែតិចទៅ។ គ្រូពេទ្យសរសៃប្រសាទរបស់លោកអ្នកនឹងពិភាក្សាជាមួយលោកអ្នកនូវមូលហេតុដែលមានការស្នើសុំ ECT សំរាប់លោកអ្នក និងការព្យាបាលមានប្រយោជន៍អ្វីទៀតដែលមានសំរាប់លោកអ្នក។ ជាការសំខាន់ណាស់ដែលលោកអ្នកទទួលព័ត៌មានឲ្យបានគ្រប់គ្រាន់អំពី ECT ។ បើលោកអ្នកមានសំណួរឬការបារម្ភណាមួយអំពី ECT សូមសួរគ្រូពេទ្យសរសៃប្រសាទរបស់លោកអ្នក ឬសមាជិកម្នាក់ទៀតនៃក្រុមព្យាបាល។

## តើ ECT ជាអ្វីទៅ?

ECT គឺជាទំរង់ការព្យាបាលមួយដែលអនុវត្តដោយវេជ្ជបណ្ឌិត។

ECT គឺជាទំរង់ការព្យាបាលមួយដែលអនុវត្តដោយវេជ្ជបណ្ឌិត។ អ្នកទទួលការព្យាបាលនេះទទួលថ្នាំសន្លប់និងថ្នាំបន្ធូរសំរាលសាច់ដុំ។ នៅពេលដែលថ្នាំទាំងនេះមានប្រសិទ្ធភាពពេញលេញហើយ ខួរក្បាលរបស់អ្នកនេះត្រូវបានកំរើកដោយចរន្តអគ្គិសនីមួយចំនួនបន្តបន្ទាប់ដែលមានរយៈពេលខ្លីនិងក្រោមការត្រួតត្រា ដោយប្រើអេឡិកត្រូដដែលដាក់នៅនឹងកន្លែងជាក់ច្បាស់លើក្បាលរបស់អ្នកនោះ។ វិធីកំរើកនេះបណ្តាលឲ្យមានការកន្ត្រាក់មួយក្នុងរង្វង់ខួរក្បាលដែលមានរយៈពេលដល់ទៅពីរនាទី។ ដោយសារតែថ្នាំបន្ធូរសំរាលសាច់ដុំនិងថ្នាំសន្លប់ រាងកាយរបស់អ្នកនោះមិនកន្ត្រាក់ទេ ហើយអ្នកនោះគ្មានអារម្មណ៍ឈឺចាប់ឡើយ។ អ្នកនោះភ្ញាក់ដឹងខ្លួននៅពេលប្រាំទៅដប់នាទីក្រោយមក សឹងតែស្រដៀងគ្នានឹងការវះកាត់តូចតាចយ៉ាងដូច្នោះដែរ។

ជាធម្មតា ECT តំរូវឲ្យធ្វើទៅចំនួនប្រាំមួយទៅដប់ពីរលើក ដោយផ្តល់ឲ្យចំនួនបីលើកក្នុងមួយអាទិត្យ នៅពេលប្រហែលមួយខែ។ គ្រូពេទ្យសរសៃប្រសាទលោកអ្នកនឹងពិភាក្សាជាមួយលោកអ្នកនូវចំនួនព្យាបាលដែលលោកអ្នកប្រហែលជាត្រូវការ។

## តើប្រើ ECT នៅពេលណា?

ECT ជាការព្យាបាលល្អសំរាប់ការសៅហ្មងចំបង ភាពឆ្កួតល្ងីល្ងើទំរង់ខ្លះនៃជំងឺស្មារតីម្យ៉ាងហៅថា schizophrenia ព្រមទាំងជំងឺផ្លូវចិត្តនិងសរសៃប្រសាទដទៃមួយចំនួនតូចទៀត។ គេប្រហែលជាប្រើវិធីនេះ នៅពេលដែលថ្នាំពេទ្យគ្មានប្រសិទ្ធភាពឡើយ។ គេប្រហែលជាប្រើវិធីនេះផងដែរសំរាប់អ្នកដែលមានផលវិបាកធ្ងន់ធ្ងរពីថ្នាំពេទ្យ ឬអ្នកមានស្ថានភាពជំងឺដែលមិនអាចឲ្យអ្នកនេះប្រើថ្នាំពេទ្យដោយសុវត្ថិភាព។ ECT ត្រូវបានប្រើផងដែរនៅក្នុងស្ថានការណ៍គំរាមកំហែងដល់អាយុជីវិត នៅពេលដែលថ្នាំពេទ្យនឹងមិនអាចដំណើរការបានរហ័សគ្រប់គ្រាន់។ វិធីនេះមានភាពល្អប្រសើរជាពិសេសសំរាប់អ្នកដែលសៅហ្មងចិត្តខ្លាំងក្លា និងអ្នកដែលអាចសម្លាប់ខ្លួនឯង។

សេចក្តីសំរេចចិត្តដើម្បីប្រើវិធី ECT ត្រូវបានផ្អែកលើការវាយតម្លៃរាងកាយនិងសរសៃប្រសាទយ៉ាងម៉ត់ចត់នៃអ្នកជំងឺ ដោយគិតអំពីប្រភេទជំងឺ កំរិតនៃការឈឺចាប់ លទ្ធផលដែលរំពឹងទទួលបាន និងការទាយជាមុននូវស្ថានភាពជំងឺរបស់ជននោះ បើគ្មានការព្យាបាលនេះទេនោះ។ នៅពេលដែលគ្រោះថ្នាក់នៃការសម្លាប់ខ្លួនឯងមានកំរិតខ្ពស់ ឬនៅពេលដែលអ្នកមានជំងឺធ្ងន់ធ្ងរមិនអាចបរិភោគអ្វីបាននោះ ECT អាចជួយសង្គ្រោះអាយុជីវិតបាន។

## អំពីផ្ទៃពោះវិញនោះ?

អ្នកត្រូវប្រាប់វេជ្ជបណ្ឌិត បើអ្នកប្រហែលជាមានផ្ទៃពោះ។ សេចក្តីសំរេចចិត្តថាតើត្រូវព្យាបាលស្ត្រីមានផ្ទៃពោះដោយប្រើ ECT ដែរឬទេត្រូវគិតផងដែរនូវគ្រោះថ្នាក់ដែលពាក់ព័ន្ធនឹងការព្យាបាលជាជំរើសផ្សេងទៀត គ្រោះថ្នាក់ចំពោះម្តាយនិងកូនក្នុងផ្ទៃក្នុងការ

មិនប្រើ ECT និងស្ថានភាពជំងឺបន្ទាប់បន្សំណាមួយដោយសារតែផ្ទៃពោះ ដែលអាចបង្កើនលទ្ធភាពគ្រោះថ្នាក់នៃ ECT ឬថ្នាំសន្លប់។

## តើ ECT អាចធ្វើឲ្យខូចខាតដល់ខួរក្បាលឬទេ?

គ្មានទេ។ គ្មានភស្តុតាងណាដែលថា ECT បណ្តាលឲ្យមានការខូចខាតដល់ខួរក្បាល ឬការផ្លាស់ប្តូរមានគ្រោះថ្នាក់ចំពោះបុគ្គលិកលក្ខណៈឡើយ។

## តើខ្ញុំត្រូវធ្វើអ្វីខ្លះមុនការព្យាបាល ECT នោះ?

លោកអ្នកមិនត្រូវទទួលទានអាហារ ជាតិទឹកឬទឹក នៅពេលយ៉ាងតិចប្រាំមួយម៉ោង មុនពេលព្យាបាល ECT ដើម្បីធ្វើឲ្យប្រាកដថាក្រពះលោកអ្នកគ្មានអ្វីសោះឡើយ។ គេហៅទង្វើនេះថា "ការតមអាហារនិងទឹក"។ បើលោកអ្នកទទួលទានអ្វីមួយក្នុងរង្វង់ពេលតមអាហារនិងទឹកនេះ លោកអ្នកត្រូវប្រាប់គិលានុបដ្ឋាកឬបុគ្គលិកពេទ្យ មុនពេលនៃការព្យាបាល។

## តើខ្ញុំនៅតែអាចប្រើថ្នាំពេទ្យបានដែរឬទេ?

វេជ្ជបណ្ឌិតរបស់លោកអ្នកប្រហែលជាផ្លាស់ប្តូរថ្នាំពេទ្យលោកអ្នក ដោយសារតែថ្នាំពេទ្យខ្លះអាចមានផលប៉ះពាល់ដល់ប្រសិទ្ធភាពនៃ ECT ។ នៅវេលាព្រឹកនៃថ្ងៃព្យាបាល លោកអ្នកប្រហែលជាទទួលថ្នាំពេទ្យខ្លះ ប៉ុន្តែប្រើជាមួយទឹកតិចក្រៃលែងតែប៉ុណ្ណោះ។

## តើ ECT ត្រូវបានធ្វើទៅតាមវិធីណា?

មុនពេលនៃការព្យាបាល ECT លើកដំបូងរបស់លោកអ្នក លោកអ្នកនឹងទទួលការពិនិត្យមើលដើម្បីធានាថា លោកអ្នកមានសុខភាពល្អគ្រប់គ្រាន់ដើម្បីទទួលថ្នាំសន្លប់មួយរយៈខ្លី និង ECT ។ បន្ទាប់មកគេនឹងសុំឲ្យលោកអ្នករង់ចាំនៅក្នុងបន្ទប់រង់ចាំ មុនពេលនាំចូលទៅក្នុងកន្លែងព្យាបាល ជាទីដែលលោកអ្នកនឹងគេងនៅលើគ្រែរទេះមួយ។ បុគ្គលិកនឹងភ្ជាប់ទៅនឹងខ្លួនលោកអ្នកនូវឧបករណ៍ដូចតទៅនេះ៖

- បន្ទះស្ទង់សម្ពាធឈាមនៅលើដៃឬជើង ឬទាំងដៃនិងទាំងជើងរបស់លោកអ្នក
- ឧបករណ៍តូចមួយនៅលើម្រាមដៃលោកអ្នកដើម្បីឆែកមើលជីពចរនិងកំរិតអុកស៊ីហ្សែននៅក្នុងឈាមលោកអ្នក
- បន្ទះស្អិតអេឡិកត្រូដតូចៗនៅលើថ្ងាសលោកអ្នក និងនៅខាងក្រោយត្រចៀកលោកអ្នក ដើម្បីកត់ត្រាសកម្មភាពអគ្គិសនីនៃខួរក្បាលលោកអ្នក ក្នុងអំឡុងពេលព្យាបាល
- ប្រដាប់ពាក់គ្របច្រមុះនិងមាត់លោកអ្នក ដើម្បីផ្តល់អុកស៊ីហ្សែនឲ្យលោកអ្នក។ ប្រដាប់នេះគឺដើម្បីរៀបចំរាងកាយនិងខួរក្បាលលោកអ្នកក្នុងការធ្វើសកម្មភាពបន្ថែមដែលនឹងកើតមានឡើងរយៈពេលខ្លីនៅពេលធ្វើការព្យាបាល។

គេប្រហែលជាប្រើគ្រឿងបរិក្ខារបន្ថែម បើមានកត្តាលទ្ធភាពគ្រោះថ្នាក់បន្ថែមទៀត ដែលដឹងតាមរយៈប្រវត្តិជំងឺ ការពិនិត្យ និងការធ្វើតេស្តលោកអ្នក។

លោកអ្នកនឹងទទួលថ្នាំសន្លប់មួយរយៈពេលខ្លី ដើម្បីឲ្យលោកអ្នកគេងលក់ និងគ្មានអារម្មណ៍ ឬចងចាំការព្យាបាល។

ថ្នាំសន្លប់នឹងត្រូវចាក់ទៅក្នុងសរសៃឈាមដើម្បីឲ្យឆាប់ដំណើរការនិងមានប្រសិទ្ធភាព។ វេជ្ជបណ្ឌិតថ្នាំសន្លប់ពិសេសម្នាក់ (គ្រូពេទ្យឯកទេសថ្នាំសន្លប់)នឹងស្ថិតនៅក្នុងបន្ទប់ព្យាបាលដើម្បីផ្តល់ថ្នាំសន្លប់ លោកអ្នកក៏នឹងទទួលថ្នាំបន្ធូរសំរាលសាច់ដុំផងដែរ។

វេជ្ជបណ្ឌិតដែលមានការបណ្តុះបណ្តាលពិសេសសំរាប់ ECT នឹងមើលខុសត្រូវការព្យាបាលនេះ។ វេជ្ជបណ្ឌិតនេះដាក់អេឡិកត្រូដតូចៗទៅលើស្បែកលលាដ៏ក្បាលលោកអ្នក និងបញ្ជូនចរន្តអគ្គិសនីតាមចំនួនដែលវាស់វែងទៅកាន់ផ្នែកមួយនៃខួរក្បាល ដើម្បីបង្កឲ្យកន្ត្រាក់។ ភាពកន្ត្រាក់នេះនឹងមានរយៈពេលដល់ទៅពីរនាទី។ ក្នុងអំឡុងពេលព្យាបាលនេះ គ្រូពេទ្យឯកទេសថ្នាំសន្លប់នឹងផ្តល់អុកស៊ីហ្សែនឲ្យលោកអ្នកតទៅទៀត តាមរយៈឧបករណ៍ពាក់គ្របមុខនិងតាមដានចង្វាក់បេះដូងនិងកំរិតអុកស៊ីហ្សែនរបស់លោកអ្នក។ គ្រូពេទ្យឯកទេសថ្នាំសន្លប់នេះនិងវេជ្ជបណ្ឌិតនឹងព្យាបាលប្រតិកម្មទំនាស់ណាមួយទៅនឹងការព្យាបាលនោះ។

លោកអ្នកនឹងគ្មានអារម្មណ៍ឬចងចាំការព្យាបាលពិតប្រាកដណាមួយទេ ដោយសារតែលោកអ្នកនឹងគេងលក់ពីព្រោះតែថ្នាំសន្លប់។ ក្នុងរង្វង់ពេលពីរបីនាទីក្រោយពីការព្យាបាលហើយ ថ្នាំសន្លប់នឹងសាបរលាប ហើយលោកអ្នកនឹងភ្ញាក់ឡើង។ ក្នុងអំឡុងពេលនេះ គេនឹងបញ្ជូនលោកអ្នកទៅកាន់បន្ទប់ដឹងខ្លួនឡើងវិញ ជាទីដែលលោកអ្នកនឹងទទួលការថែទាំរហូតទាល់តែលោកអ្នកភ្ញាក់ដឹងខ្លួនគ្រប់គ្រាន់ដើម្បីវិលទៅកាន់អគាររបស់លោកអ្នកវិញ។ បើលោកអ្នកទទួលទំរង់ការ ECT នៅពេលថ្ងៃ លោកអ្នកប្រហែលជាត្រូវរង់ចាំនៅក្នុងបន្ទប់រង់ចាំឬអគារមួយរយៈពេលដល់ទៅបួនប្រាំម៉ោង ដើម្បីធ្វើឲ្យប្រាកដថា លោកអ្នករៀបចំខ្លួនជាស្រេចដើម្បីវិលទៅផ្ទះវិញ។

ក្រោយពីលោកអ្នកភ្ញាក់ឡើងវិញហើយ ថ្នាំសន្លប់និងភាពកន្ត្រាក់នឹងធ្វើឲ្យលោកអ្នកធីងធោងមួយរយៈកាល។ ជាធម្មតាលោកអ្នកនឹងអាចបរិភោគអាហារបាន នៅពេលប្រហែល 15-20 នាទី ក្រោយពីការព្យាបាល។

## តើអ្វីទៅដែលលទ្ធភាពគ្រោះថ្នាក់និងប្រយោជន៍នៃ ECT?

គ្រូពេទ្យសរសៃប្រសាទលោកអ្នកនឹងពិភាក្សាជាមួយលោកអ្នកនូវប្រយោជន៍របស់ ECT ដែលរំពឹងទទួលបាន។ ប្រយោជន៍ទាំងនេះនឹងមានភាពខុសៗគ្នាដោយផ្អែកលើលក្ខណៈនិងភាពធ្ងន់ធ្ងរនៃជំងឺរបស់លោកអ្នក ប៉ុន្តែជាទូទៅ ECT នឹងកែលំអសមត្ថភាពលោកអ្នកក្នុងការគិតគូរ និងធ្វើឲ្យអារម្មណ៍របស់លោកអ្នកវិលទៅកាន់ស្ថានភាពល្អប្រសើរជាងមុន។

ការព្យាបាលទាំងអស់មានលទ្ធភាពគ្រោះថ្នាក់និងផលវិបាក ប៉ុន្តែការមិនព្យាបាលក៏មានលទ្ធភាពគ្រោះថ្នាក់ដែរ។ លទ្ធភាពគ្រោះថ្នាក់និងផលវិបាកនៃ ECT មានរួមទាំង៖

- លោកអ្នកប្រហែលជាមានផលវិបាកខ្លះពីថ្នាំសន្លប់ ដូចជា ឈឺក្បាលចង្អោរ ក្អួតជាដើម។ លោកអ្នកគួរប្រាប់បុគ្គលិកដែលថែទាំលោកអ្នក ហើយបុគ្គលិកនោះនឹងអាចផ្តល់ថ្នាំពេទ្យជាជំនួយខ្លះជូនលោកអ្នក។
- សាច់ដុំលោកអ្នកប្រហែលជាមានភាពឈឺចាប់ខ្លះ ដោយសារតែជាលទ្ធផលនៃថ្នាំបន្ធូរសំរាលសាច់ដុំឬសកម្មភាពសាច់ដុំដែលបណ្តាលដោយការកន្ត្រាក់។

- ថ្នាំសន្លប់នឹងមានផលប៉ះពាល់ដល់ការវិនិច្ឆ័យរបស់លោកអ្នក អស់ពេល 24 ម៉ោង។ ក្នុងអំឡុងពេលនេះ **លោកអ្នកមិនត្រូវ៖**
  - **បើកបរយានយន្តប្រភេទណាមួយទេ**
  - **ប្រតិបត្តិការគ្រឿងម៉ាស៊ីន ដោយមានរួមទាំងគ្រឿងចំអិនអាហារ**
  - **ធ្វើសេចក្ដីសំរេចចិត្តសំខាន់ទាំងឡាយ ឬក៏ចុះហត្ថលេខាលើឯកសារផ្លូវច្បាប់ណាមួយឡើយ**
  - **សេពសុរាឬប្រើសារធាតុឯទៀតដែលកែប្រែស្មារតី ឬជក់បារីទេ ដោយសារតែសារធាតុទាំងនោះអាចធ្វើប្រតិកម្មជាមួយថ្នាំសន្លប់។**
- ស្មារតីចងចាំរយៈពេលខ្លីរបស់លោកអ្នកប្រហែលជាទទួលផលប៉ះពាល់៖
  - ក្រោយពី ECT មួយរំពេចនោះ មនុស្សភាគច្រើនមានការភាន់ច្រឡំមួយរយៈពេលខ្លី ហើយមិនចងចាំការព្យាបាលពិតប្រាកដទេ។
  - នៅពេលទទួលវគ្គព្យាបាលនៃ ECT លោកអ្នកប្រហែលជាលំបាកចងចាំព័ត៌មានដែលដឹងនៅពេលថ្មីៗ ទោះជាការលំបាកនេះបាត់ទៅវិញនៅពេលជាច្រើនថ្ងៃនិងអាទិត្យ បន្ទាប់ពីបញ្ចប់ការព្យាបាល ECT មួយវគ្គក៏ដោយ។ អ្នកខ្លះក៏រាយការណ៍អំពីការបាត់បង់ការចងចាំខ្លះនូវព្រឹត្តិការណ៍ដែលបានកើតមានឡើងក្នុងអំឡុងពេលប៉ុន្មានថ្ងៃ ប៉ុន្មានអាទិត្យ និងប៉ុន្មានខែ មុនពេល ECT ។ ជាធម្មតាភាគច្រើននៃការចងចាំទាំងនេះវិលមកវិញនៅពេលប៉ុន្មានថ្ងៃឬប៉ុន្មានខែ ក្រោយពី ECT ប៉ុន្តែអ្នកខ្លះបានរាយការណ៍អំពីបញ្ហាដែលមានរយៈពេលយូរ ក្នុងការរំលឹកឡើងវិញនូវការចងចាំទាំងនេះដែរ។ ECT មិនទំនងជាមានផលប៉ះពាល់ដល់ការចងចាំព្រឹត្តិការណ៍ពីអតីតកាលរបស់លោកអ្នកឡើយ។
  - ទោះជាការចងចាំជាក់លាក់នៅជុំវិញពេលដែលលោកអ្នកទទួល ECT ប្រហែលជាមិនវិលមកវិញក្តី ក៏ការចងចាំសរុបរបស់លោកអ្នកនឹងដំណើរការកាន់តែល្អឡើង នៅពេលប៉ុន្មានអាទិត្យ និងប៉ុន្មានខែក្រោយពីការព្យាបាលនោះ។
  - វេជ្ជបណ្ឌិតលោកអ្នកដឹងអំពីលទ្ធភាពនៃបញ្ហាចងចាំ ហើយនឹងចេញវេជ្ជបញ្ជាឲ្យមានវិធីព្យាបាលដែលផ្តល់លោកអ្នកនូវការព្យាបាលល្អបំផុត ដែលនឹងចៀសវាងការប៉ះពាល់ដល់ការចងចាំរបស់លោកអ្នកឲ្យបានច្រើនតាមលទ្ធភាព។
- ផលវិបាកខ្លះទៀតមិនសូវកើតមានទេ ហើយខ្លះទៀតកំរកើតមានណាស់៖
  - មានលទ្ធភាពគ្រោះថ្នាក់មិនសូវទូទៅនៃបញ្ហាបន្ទាប់បន្សំទាំងឡាយ ដូចជាដំណើរនិងចង្វាក់បេះដូងមិនប្រក្រតី។ ប្រហែលជាមានកំណើនបណ្តោះអាសន្ននូវសម្ពាធឈាម និងដំណើរបេះដូង ហើយនិងដំណើរបេះដូងយឺតនៅគ្រាបន្ទាប់ពីនោះ។
  - លទ្ធភាពគ្រោះថ្នាក់តិចតួចនៃការបាត់បង់ជីវិត គឺមានដូចគ្នានឹងថ្នាំសន្លប់ណាមួយទៀតដែរ ប៉ុន្តែដោយមាន ECT ទំនើប និងថ្នាំសន្លប់មួយរយៈពេលខ្លី ឥឡូវនេះលទ្ធភាពគ្រោះថ្នាក់នេះកំរកើតមានណាស់។ ការគាំងបេះដូង ដាច់សរសៃឈាម ឬរបួសទាក់ទងនឹងការកន្ត្រាក់សាច់ដុំ ក៏កំរកើតមានណាស់ផងដែរ។ មន្ទីរពេទ្យមានជាបន្ទាន់នូវគ្រឿងបរិក្ខារឲ្យមានដំណើរដកដង្ហើមឡើងវិញ និងទំរង់ការគ្រាអាសន្ន បើបញ្ហាមិនល្អណាមួយកើតមានឡើង។

## តើខ្ញុំត្រូវការការព្យាបាលបន្ថែមទៀតឬទេ?

នៅក្នុងពេលដែលជំងឺរបស់លោកអ្នកប្រហែលជាសះស្បើយតាមរយៈ ECT មួយក៏រិតសព្វគ្រប់ ក៏ជំងឺនេះប្រហែលជាវិលមកវិញនៅពេលបានបញ្ចប់ក៏រិតសព្វគ្រប់នេះ។ ដើម្បីជួយបង្ការកុំឲ្យហេតុការណ៍នេះកើតមានឡើង វេជ្ជបណ្ឌិតលោកអ្នកនឹងពិភាក្សាជាមួយលោកអ្នកនូវការព្យាបាលបន្ថែមណាមួយដែលលោកអ្នកប្រហែលត្រូវការ ក្រោយពីបានបញ្ចប់ ECT មួយវគ្គ ដូចជា៖

- ការប្រើថ្នាំពេទ្យ
- ការរក្សា ECT
- ការព្យាបាលសរសៃប្រសាទ។

## បណ្តឹង

លោកអ្នកគួរទទួលការប្រព្រឹត្តអំពើមកលើដែលប្រកបដោយកិត្តិយសនិងការគោរព និងត្រូវបានការពារទល់នឹងការប្រព្រឹត្តអំពើមិនគប្បីមកលើ នៅពេលលោកអ្នកទទួល ECT ។ បើលោកអ្នកមិនពេញចិត្តអំពីផ្នែកណាមួយនៃការព្យាបាលឬការថែទាំលោកអ្នកទេ លោកអ្នកអាចធ្វើបណ្តឹងបាន។ កន្លែងល្អសំរាប់ចាប់ផ្តើមគឺជាមួយប្រធានករណីលោកអ្នក គិលានុបដ្ឋាកសំខាន់ ឬសមាជិកម្នាក់ទៀតនៃក្រុមព្យាបាល មន្ត្រីទំនាក់ទំនងបណ្តឹង ឬអ្នកពិគ្រោះយោបល់អ្នកប្រើប្រាស់នៅក្នុងមន្ទីរពេទ្យ វេជ្ជបណ្ឌិតឬគ្រូពេទ្យសរសៃប្រសាទលោកអ្នក ឬនាយកផ្នែកសរសៃប្រសាទនៅឯសេវាសុខភាពផ្លូវចិត្ត។

លោកអ្នកក៏អាចធ្វើបណ្តឹងដោយផ្ទាល់ទៅកាន់ស្នងការសេវាសុខភាព *(Health Services Commissioner)* ផងដែរ តាមទូរស័ព្ទលេខ 8601 5200 ឬប្រធានគ្រូពេទ្យសរសៃប្រសាទ តាមលេខ 1300 767 299 ។

បើលោកអ្នកត្រូវការជំនួយក្នុងការធ្វើបណ្តឹងរបស់លោកអ្នក លោកអ្នកអាចសុំជំនួយពីជនណាមួយដែលលោកអ្នកទុកចិត្ត។ ជននេះប្រហែលជាសមាជិកនៃក្រុមព្យាបាល មិត្តភក្តិសមាជិកគ្រួសារ មេធាវី ឬអ្នកសាកសួរសុខទុក្ខមកពីសហគមន៍។

# ការទាក់ទងសំខាន់ៗ

អង្គការទាំងឡាយដែលលោកអ្នកអាចទាក់ទងសុំជំនួយ និងទទួលព័ត៌មានបន្ថែមមានរាយឈ្មោះនៅខាងក្រោមនេះ។

- **អ្នកសាកសួរសុខទុក្ខមកពីសហគមន៍** ***(Community visitors)*** គឺជាអ្នកដែលអញ្ជើញទៅកាន់សេវាសុខភាពផ្លូវចិត្តយ៉ាងតិចក៏ម្តងដែរក្នុងមួយខែ ដើម្បីសាកសួរអំពីភាពគ្រប់គ្រាន់នៃសេវានិងគ្រឿងប្រដាប់ប្រដារ សំរាប់ការព្យាបាលនិងការថែទាំអ្នកជំងឺ ស៊ើបអង្កេតបណ្តឹង និងរាយការណ៍អំពីការសាកសួរនិងការស៊ើបអង្កេតរបស់ខ្លួន។

  5th Floor, 436 Lonsdale Street, Melbourne 3000
  ទូរស័ព្ទ៖ 9603 9500
  ទូរស័ព្ទឥតគិតថ្លៃ៖ 1300 309 337

- **មណ្ឌលផ្នែកច្បាប់សុខភាពផ្លូវចិត្ត** ***(Mental Health Legal Centre)*** គឺជាសេវាឯករាជ្យផ្នែកច្បាប់ដែលមានឯកទេសខាងបញ្ហាច្បាប់សុខភាពផ្លូវចិត្ត។ មណ្ឌលនេះអាចរៀបចំធ្វើជាតំណាងជូនលោកអ្នកនៅឯការស្តាប់ក្តីរបស់ក្រុមប្រឹក្សាពិនិត្យមើលឡើងវិញលើសុខភាពផ្លូវចិត្ត ឬផ្តល់ឱវាទអំពីបញ្ហាផ្លូវច្បាប់ផ្សេងទៀត។

  9th Floor, 10–16 Queen Street, Melbourne 3000
  ទូរស័ព្ទ៖ 9629 4422
  ទូរស័ព្ទឥតគិតថ្លៃ៖ 1800 555 887

- **ជំនួយផ្នែកច្បាប់រដ្ឋវិចតូរីយ៉ា** ***(Victoria Legal Aid)*** ផ្តល់ឱវាទផ្នែកច្បាប់ដោយឥតគិតថ្លៃអំពីបញ្ហាផ្សេងៗគ្នាជាច្រើន។ ស្ថាប័ននេះក៏ផ្តល់ជំនួយផ្នែកច្បាប់ផងដែរ បើលោកអ្នកគ្មានប្រាក់ជួលមេធាវីឯកជនបាន ហើយក៏អាចជួយឡើងបកស្រាយផ្នែកច្បាប់នៅឯការប្រជុំរបស់ក្រុមប្រឹក្សាពិនិត្យមើលឡើងវិញផ្នែកសុខភាពផ្លូវចិត្តផងដែរ។

  350 Queen Street, Melbourne 3000
  ទូរស័ព្ទ៖ 9269 0234
  ទូរស័ព្ទឥតគិតថ្លៃ៖ 1800 677 402

- **អ្នកគាំទ្រសាធារណៈ** ***(Public Advocate)*** ជួយផ្តល់ឱវាទនិងគាំទ្រអ្នកដែលមានបណ្តឹងធ្ងន់ធ្ងរអំពីសេវានិងការព្យាបាលសុខភាពផ្លូវចិត្តនិងពិការភាព។

  5th Floor, 436 Lonsdale Street, Melbourne 3000
  ទូរស័ព្ទ៖ 9603 9500
  ទូរស័ព្ទឥតគិតថ្លៃ៖ 1300 309 337

- **គណៈកម្មការឱកាសស្មើគ្នានិងសិទ្ធិមនុស្សរដ្ឋវិកតូរីយ៉ា** ***(Victorian Equal Opportunity and Human Rights Commission)*** ជួយបណ្តាជនក្នុងការដោះស្រាយបណ្តឹងអំពីការប្រកាន់រើសអើង មានមុខងារជាក់លាក់ដែលទាក់ទងនឹងលក្ខន្តិកៈនៃសិទ្ធិមនុស្សនិងការទទួលខុសត្រូវ ហើយអាចផ្តល់ឱវាទអំពីលក្ខន្តិកៈនេះ។

  សេវាទាំងពួងមានរួមទាំងទូរស័ព្ទសាកសួរ និងសេវាដោះស្រាយបណ្តឹងដោយលាក់ការ ឥតគិតថ្លៃ និងមិនលំអៀង។

  Level 3, 380 Lonsdale Street, Melbourne 3000
  ទូរស័ព្ទ៖ 9281 7100
  ទូរស័ព្ទឥតគិតថ្លៃ៖ 1800 13 41 42
  វ៉ិបសៃ៖ www.humanrightscommission.vic.gov.au

- **ប្រធានគ្រូពេទ្យសរសៃប្រសាទ** ***(Chief Psychiatrist)*** គឺជាមន្ត្រីជាន់ខ្ពស់នៃក្រសួងសេវាពលរដ្ឋ ដែលតែងតាំងនៅក្រោមច្បាប់សុខភាពផ្លូវចិត្ត ដោយមានការទទួលខុសត្រូវពិសេសទាក់ទងនឹងអ្នកទទួលសេវាសុខភាពផ្លូវចិត្ត។ ការទទួលខុសត្រូវទាំងនេះ មានរួមទាំងអំណាចដើម្បីស៊ើបអង្កេតបណ្តឹងនិងបញ្ហាឯទៀតនិងដើម្បីចាត់ឲ្យមានវិធានការចាំបាច់ព្រមទាំងការតាមដានការប្រើប្រាស់ ECT នៅក្នុងរដ្ឋវិចតូរីយ៉ា។

  50 Lonsdale Street, Melbourne 3000
  ទូរស័ព្ទ៖ 9096 7571
  ទូរស័ព្ទឥតគិតថ្លៃ៖ 1300 767 299

- **ស្នងការសេវាសុខភាព** ***(Health Services Commissioner)*** គឺជាស្នងការមិនប្រកាន់ខាងណាដែលស៊ើបអង្កេតនិងជួយដោះស្រាយបណ្តឹងដោយអ្នកប្រើប្រាស់ការថែទាំសុខភាព អំពីសេវាសុខភាព ដោយមានរួមទាំងសេវាសុខភាពផ្លូវចិត្ត។ ស្នងការនេះអាចជួយអ្នកជំងឺដើម្បីទទួលព័ត៌មានអំពីសុខភាពរបស់ខ្លួន។

  30th Floor, 570 Bourke Street, Melbourne 3000
  ទូរស័ព្ទ៖ 8601 5200
  ទូរស័ព្ទឥតគិតថ្លៃ៖ 1800 136 066

- **មន្ត្រីស៊ើបអង្កេតបណ្តឹងអំពីមន្ត្រីរដ្ឋការ** ***(Ombudsman)*** ស៊ើបអង្កេតបណ្តឹងអំពីក្រសួងរបស់រដ្ឋាភិបាល។

  3rd Floor, 459 Collins Street, Melbourne 3000
  ទូរស័ព្ទ៖ 9613 6222
  ទូរស័ព្ទឥតគិតថ្លៃ៖ 1800 806 314

- **ក្រុមប្រឹក្សាពិនិត្យមើលឡើងវិញអំពីសុខភាពផ្លូវចិត្ត** ***(Mental Health Review Board)*** គឺជាសាលាក្តីមិនប្រកាន់ភាគីខាងណាមួយដែលស្តាប់បណ្តឹងតវ៉ាពីអ្នកជំងឺមិនស្ម័គ្រចិត្ត អ្នកជំងឺក្រោមបញ្ជាព្យាបាលមិនស្ម័គ្រចិត្តដែលមានកំរិតកំណត់ និងអ្នកជំងឺជាប់ឃុំឃាំងក្នុងសេវាសុខភាពផ្លូវចិត្តដែលចង់ចេញពីស្ថានភាពព្យាបាលដោយមិនស្ម័គ្រចិត្តរបស់ខ្លួន។ ក្រុមប្រឹក្សានេះក៏ពិនិត្យមើលឡើងវិញនូវអ្នកជំងឺទាំងនេះដោយស្វ័យប្រវត្តិផងដែរ។

  Level 30, Marland House,
  570 Bourke Street, Melbourne 3000
  ទូរស័ព្ទ៖ 8601 5270
  ទូរស័ព្ទឥតគិតថ្លៃ៖ 1800 242 703
  ទូរសារ៖ 8601 5299
  អ៊ីមែល៖ mhrb@mhrb.vic.gov.au
  វ៉ិបសៃ៖ www.mhrb.vic.gov.au

លោកអ្នកក៏អាចសាកសួរប្រធានករណីរបស់លោកអ្នក ឬសមាជិកណាមួយនៃក្រុមព្យាបាលផងដែរ អំពីអង្គការឯទៀតក្នុងតំបន់ និងក្រុមជំនួយទាំងឡាយ ដែលអាចជួយលោកអ្នកបាន។

## កូនសៀវភៅដែលបោះផ្សាយជាស៊េរី “អំពីសិទ្ធិរបស់លោកអ្នក”៖

- អ្នកជំងឺមិនស្ម័គ្រចិត្ត *(Involuntary patients)*
- បញ្ជាឲ្យទទួលការព្យាបាលដោយមិនស្ម័គ្រចិត្តក្រោមការត្រួតពិនិត្យ *(Restricted involuntary treatment orders)*
- អ្នកជំងឺជាប់ឃុំឃាំង *(Security patients)*
- អ្នកជំងឺនីតិក្រម *(Forensic patients)*
- ការព្យាបាលដោយវិធីឆក់ខ្សែភ្លើង *(Electroconvulsive therapy)*
- ការព្យាបាលចំបងដែលមិនពាក់ព័ន្ធនឹងជំងឺសរសៃប្រសាទ *(Major non-psychiatric treatment)*
- បញ្ជាមើលខុសត្រូវមិននៅក្រោមការឃុំឃាំង *(Non-custodial supervision orders)*

## កូនសៀវភៅផ្សេងទៀតនៅក្នុងស៊េរី “អំពីសិទ្ធិរបស់លោកអ្នក”៖

- អ្នកជំងឺនីតិក្រម (បញ្ជាឃុំខ្លួននិងមើលខុសត្រូវបណ្តោះអាសន្ន) *(Forensic (remand and interim disposition order) patients)*
- អ្នកជំងឺមិនស្ម័គ្រចិត្តបន្តការព្យាបាលតទៅទៀត (មាត្រាទី 12A – 12D) *(Continuing treatment (section 12A-12D) involuntary patients)*
- បញ្ជាពិនិត្យវាយតម្លៃ និងបញ្ជារោគវិនិច្ឆ័យ ពិនិត្យវាយតម្លៃនិងព្យាបាល *(Assessment orders and diagnosis, assessment and treatment orders)*
- ការវះកាត់ព្យាបាលរោគផ្លូវចិត្ត *(Psychosurgery)*

កូនសៀវភៅទាំងនេះនិងកូនសៀវភៅឯទៀត មាននៅតាមវ៉ិបសៃ www.health.vic.gov.au/mentalhealth ដោយមានអក្សរធំៗ។

មានកូនសៀវភៅមួយចំនួនជាភាសាផ្សេងទៀតផងដែរ។

## សេវាទូរស័ព្ទផ្តល់ព័ត៌មាន

លោកអ្នកអាចស្តាប់ព័ត៌មានថតទុកអំពីការព្យាបាលដោយវិធីឆក់ខ្សែភ្លើងជាភាសាមួយចំនួន តាមរយៈការទូរស័ព្ទទៅកាន់សេវាទូរស័ព្ទផ្តល់ព័ត៌មាន។

សេវាទូរស័ព្ទនេះធ្វើការ 24 ម៉ោងក្នុងមួយថ្ងៃ ប្រាំពីរថ្ងៃក្នុងមួយអាទិត្យ។

| | |
|---|---|
| អង់គ្លេស | 9679 9838 |
| អារ៉ាប់ | 9679 9825 |
| ខ្មែរ | 9679 9826 |
| ចិនកន្តាំង | 9679 9827 |
| ក្រូអាត | 9679 9828 |
| ក្រិក | 9679 9829 |
| អ៊ីតាលី | 9679 9830 |
| ម៉ាសេដូនី | 9679 9831 |
| ចិនកុកងឺ | 9679 9837 |
| ស៊ែប៊ី | 9679 9834 |
| សូម៉ាលី | 9679 9832 |
| អេស្ប៉ាញ | 9679 9833 |
| ទួរគី | 9679 9835 |
| វៀតណាម | 9679 9836 |

បោះពុម្ពផ្សាយដោយផ្នែកសុខភាពផ្លូវចិត្តនិងឱសថ (Mental Health and Drugs Division) ក្រសួងសេវាពលរដ្ឋរបស់រដ្ឋាភិបាលរដ្ឋវិកតូរីយ៉ា ក្រុងមែលប៊ន រដ្ឋវិចតូរីយ៉ា ប្រទេសអូស្ត្រាលី។

© សិទ្ធិចំលងនៃរដ្ឋវិចតូរីយ៉ា ក្រសួងសេវាពលរដ្ឋ ឆ្នាំ 2008 ។ .

អាចផលិតឡើងវិញនូវឯកសារនេះ ជាផ្នែកឬទាំងស្រុង បើមានការទទួលស្គាល់សិទ្ធិចំលង។

ខែកញ្ញា 2008 (080519)

អនុញ្ញាតដោយរដ្ឋាភិបាលរដ្ឋវិចតូរីយ៉ា ក្រុងមែលប៊ន។

### តើលោកអ្នកត្រូវការកូនសៀវភៅនេះតាមទំរង់មួយទៀតឬទេ?

បើលោកអ្នកត្រូវការកូនសៀវភៅនេះជាទំរង់មួយទៀត លោកអ្នកគួរពិភាក្សាជាមួយប្រធានករណីលោកអ្នក ឬសមាជិកណាមួយនៃក្រុមព្យាបាល។

State Government Victoria
Department of Human Services